អត្ថបទជំនួយស្មារតី

ស្តីពី

# ការគ្រប់គ្រងទ្រព្យសម្បត្តិ របស់បុគ្គលដែលអវត្តមាន និងការប្រកាសអំពីការបាត់ខ្លួន


រៀបរៀងដោយ

លោក សំបាន គូវ៉ាន់

(ជំនួយការផ្នែកច្បាប់)



នាំមកជូនដោយ ៖ នីតិកោសល

ខែសីហា ឆ្នាំ២០២០

# ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន

- **គោលបំណង** ៖ ដើម្បីការពារទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និងជៀសវាងការយកទៅចាត់ចែងដោយខុសច្បាប់ ឬ អាចនិយាយម្យ៉ាងទៀតថាគឺជាវិធានការបឋមក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលនោះជាបណ្ដោះអាសន្នមុននឹងនឹងធ្វើការចាត់ចែងតាមអានុភាពនៃការបាត់ខ្លួន។
- **លក្ខខណ្ឌ** ៖ ចេញពីលំនៅឋាន ឬ ទីសំណាក់ហើយគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួល និងមិនបានចាត់តាំងអ្នកគ្រប់គ្រង។
- **មធ្យោបាយ** ៖ ដោយការចាត់តាំងរបស់បុគ្គលដែលអវត្តមាន និងជ្រើសតាំងដោយតុលាការតាមពាក្យសុំរបស់បុគ្គលដែលមានប្រយោជន៍ មេឃុំ/ចៅសង្កាត់ អយ្យការ។



# ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន (ត)

- **សិទ្ធិរបស់អ្នកគ្រប់គ្រង** ៖ ថែរក្សា និងកែលម្អ (ម.៣៦៦-២ ក្រមរដ្ឋប្ប.) និងធ្វើសកម្មភាពផ្សេងៗបានដោយទទួលការអនុញ្ញាតពីតុលាការ។ តុលាការអាចផ្តល់កម្រៃចំនួនសមរម្យ ដល់អ្នកគ្រប់គ្រងដោយយកពីទ្រព្យសម្បត្តិរបស់អ្នកអវត្តមាន។
- **ការផ្លាស់ប្តូរអ្នកគ្រប់គ្រង** ៖ តុលាការអាចសម្រេចផ្លាស់ប្តូរអ្នកគ្រប់គ្រងដែលត្រូវបានចាត់តាំងដោយបុគ្គលដែល អវត្តមានបានតាមពាក្យសុំពីបុគ្គលដែលមានប្រយោជន៍ មេឃុំ/ចៅសង្កាត់ និងអយ្យការ។
- **ការលុបចោល** ៖ ប្រសិនបើក្រោយមកបុគ្គលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង នោះតុលាការអាចលុបចោលការបង្គាប់របស់ខ្លួនតាមពាក្យសុំ។

# ការប្រកាសអំពីការបាត់ខ្លួន

- **គោលបំណង** ៖ ដើម្បីធ្វើការចាត់ចែងទ្រព្យសម្បត្តិ និងបញ្ចប់ទំនាក់ទំនងអាពាហ៍ពិពាហ៍។

- **លក្ខខណ្ឌ** ៖ មានពីរ គឺ រយៈពេល (៥ ឆ្នាំ និង ១ឆ្នាំ) និងបុព្វហេតុ (ពុំមានដំណឹងច្បាស់លាស់ និងការចូលទៅក្នុងតំបន់សង្គ្រាម នាវាលិច ឬ ជួបគ្រោះថ្នាក់ផ្សេងទៀត)។

- **មធ្យោបាយ** ៖ ប្រកាសដោយតុលាការ តាមពាក្យសុំរបស់ សហព័ទ្ធ ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានអំណាចមេបា អ្នកអាណាព្យាបាល ឬ អ្នកផ្សេងទៀតមានប្រយោជន៍សំខាន់។



# ការប្រកាសអំពីការបាត់ខ្លួន (ត)

- **នីតិវិធី** ៖ ការដាស់តឿនជាសាធារណៈ ០៦ខែ សម្រាប់លក្ខខណ្ឌ ៥ឆ្នាំ និង ០២ខែ សម្រាប់លក្ខខណ្ឌ ១ឆ្នាំ (ម. ៥៤ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីមិនមែនបណ្តឹង) បន្ទាប់ពីដីកាសម្រេចចូលជាស្ថាពរ (២ សប្តាហ៍ ម. ៤០ ច្បាប់ដដែល)។
- **អានុភាព** ៖ ត្រូវបានចាត់ទុកថាទទួលមរណភាព ហើយអនុវត្តទំនាក់ទំនងគតិយុត្តិជុំវិញលំនៅឋាន ឬទីសំណាក់កន្លងមករហូតមកដល់ពេលនោះ។
- **ការលុបចោលដីកាសម្រេច** ៖ ប្រសិនបើមានការបញ្ជាក់ថាលក្ខខណ្ឌនៃការប្រកាសបាត់ខ្លួនខុសពីការពិតនោះតុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួនតាមពាក្យសុំរបស់សាមីជន ឬ បុគ្គលដែលមានផលប្រយោជន៍។



# ការប្រកាសអំពីការបាត់ខ្លួន (ត)

- **អានុភាពនៃការលុបចោល** ៖ បុគ្គលទទួលទ្រព្យដោយចំពោះត្រូវបាត់បង់សិទ្ធិ ហើយត្រូវសងត្រឹមកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅសល់ (បើសុច្ចរិត)។
- **អានុភាពនៃសកម្មភាពដែលបានធ្វើឡើង** ៖ សកម្មភាពដែលបុគ្គលទទួលទ្រព្យបានធ្វើមុនពេលដែលមានការលុបចោលការប្រកាស់បាត់ខ្លួន នៅតែមានសុពលភាព (បើសុច្ចរិត) ផ្ទុយទៅវិញបើធ្វើក្រោយការលុបចោលការបាត់ខ្លួន នោះគ្មានសុពលភាពនោះឡើយ។
- **អានុភាពចំពោះអាពាហ៍ពិពាហ៍ថ្មី** ៖ អាពាហ៍ពិពាហ៍មុនត្រូវរលាយដោយអាពាហ៍ ពិពាហ៍ក្រោយទោះបីជាមានការលុបចោលការបាត់ខ្លួនក៏ដោយ។

**សូមអរគុណ**

